Behaviour code for students

# ច្បាប់ឥរិយាបថសម្រាប់សិស្ស

## ព័ត៌មានសម្រាប់មាតាបិតា/អ្នកថែទាំ និងសិស្ស

សាលារដ្ឋ NSW បានប្តេជ្ញាចិត្តដើម្បីផ្តល់បរិយាកាសរៀនសូត្រដែលមានសុវត្ថិភាព ការគាំទ្រ និងការឆ្លើយតប សម្រាប់មនុស្សរាល់រូប។ យើងបង្រៀន និងធ្វើគំរូឥរិយាបថដែលយើងឱ្យតម្លៃចំពោះសិស្សរបស់យើង។

នៅតាមសាលារដ្ឋ NSW សិស្សត្រូវបានរំពឹងថានឹង៖

- គោរពសិស្សដទៃទៀត គ្រូបង្រៀនរបស់ខ្លួន និងបុគ្គលិក និងសមាជិកសហគមន៍សាលា។
- អនុវត្តតាមវិន័យសាលា និងថ្នាក់រៀន ហើយធ្វើតាមការណែនាំរបស់គ្រូខ្លួន។
- ប្រឹងប្រែងសម្រេចឲ្យបានស្តង់ដារខ្ពស់បំផុតក្នុងការរៀនសូត្រ។
- គោរពសមាជិកទាំងអស់នៃសហគមន៍សាលា ហើយសម្តែងការគួរសមចំពោះសិស្ស គ្រូ និងសមាជិកសហគមន៍ទាំងអស់។
- ដោះស្រាយជម្លោះដោយការគោរព ស្មៀមស្ងាត់ និងយុត្តិធម៌ត្រឹមត្រូវ។
- អនុវត្តតាមគោលនយោបាយឯកសណ្ឋានសាលា ឬច្បាប់ស្តីពីការស្លៀកពាក់របស់សាលា។
- មករៀនរៀងរាល់ថ្ងៃ (លុះត្រាតែត្រូវបានលើកលែងស្របច្បាប់)។
- គោរពថែរក្សាទ្រព្យសម្បត្តិទាំងអស់។
- មិនត្រូវប្រើអំពើហិង្សា ឬនាំយកអាវុធ គ្រឿងញៀនខុសច្បាប់ គ្រឿងស្រវឹង ឬថ្នាំជក់ចូលក្នុងសាលារបស់យើង។
- មិនត្រូវសម្លុត បៀតបៀន បំភិតបំភ័យ ឬប្រកាន់រើសអើងចំពោះនរណាម្នាក់នៅក្នុងសាលារបស់យើង។

សាលាចាត់វិធានការយ៉ាងតឹងរ៉ឹងក្នុងការឆ្លើយតបទៅនឹងឥរិយាបថដែលប៉ះពាល់ដល់ខ្លួនឯង ឬអ្នកដទៃទៀត ឬសមិទ្ធផលនៃការបង្រៀន និងការសិក្សាប្រកបដោយគុណភាពខ្ពស់។

## សេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកចង់ពិភាក្សាពីឯកសារនេះជាមួយនាយកសាលា និងត្រូវការជំនួយផ្នែកភាសាអង់គ្លេស សូមទូរស័ព្ទទៅសេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ប្រាប់គេអំពីភាសាមួយណាដែលលោកអ្នកត្រូវការ ហើយស្នើសុំប្រតិបត្តិករទូរស័ព្ទទៅសាលា។ ប្រតិបត្តិករនឹងភ្ជាប់លោកអ្នកទៅអ្នកបកប្រែភាសាតាមទូរស័ព្ទ ដើម្បីជួយលោកអ្នកធ្វើការសន្ទនា។ លោកអ្នកនឹងមិនត្រូវបង់ថ្លៃសម្រាប់សេវានេះទេ។

# ក្រមឥរិយាបថសម្រាប់សិស្ស៖ សកម្មភាព

ការលើកកម្ពស់ការសិក្សា សុខុមាលភាព និងសុវត្ថិភាពរបស់សិស្សទាំងអស់នៅក្នុងសាលារដ្ឋ NSW គឺជាអាទិភាពខ្ពស់សម្រាប់ Department of Education។

យើងអនុវត្តវិធីសាស្ត្របង្រៀន និងសិក្សាដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ជំនាញដែលសិស្សត្រូវការ ដើម្បីបំពេញតាមបទដ្ឋានខ្ពស់របស់យើងសម្រាប់ឥរិយាបថប្រកបដោយការគោរព សុវត្ថិភាព និងការចូលរួម។

## ការគោរព

- ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយសេចក្ដីថ្លៃថ្នូរ។
- និយាយ និងប្រកាន់ឥរិយាបថដោយរាក់ទាក់។
- សហការជាមួយអ្នកដទៃ។
- បង្កើតទំនាក់ទំនងវិជ្ជមានប្រកបដោយការគោរព និងគិតអំពីផលប៉ះពាល់លើទំនាក់ទំនងមុនពេលអនុវត្ត។
- ឲ្យតម្លៃទៅលើផលប្រយោជន៍ សមត្ថភាព និងវប្បធម៌របស់អ្នកដទៃ។
- ស្លៀកពាក់យ៉ាងត្រឹមត្រូវដោយអនុវត្តតាមវិន័យឯកសណ្ឋានសាលា ឬវិន័យការស្លៀកបំពាក់របស់សាលា។
- យកចិត្តទុកដាក់ចំពោះទ្រព្យសម្បត្តិ។

## សុវត្ថិភាព

- ធ្វើជាគំរូ និងធ្វើតាមក្រមប្រតិបត្តិ និងឥរិយាបថរបស់ក្រសួង សាលារៀន និង/ឬថ្នាក់រៀន។
- ចរចា និងដោះស្រាយជម្លោះដោយការយោគយល់អធ្យាស្រ័យ។
- ទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះឥរិយាបថ និងសកម្មភាព។
- យកចិត្តទុកដាក់ចំពោះខ្លួនឯង និងអ្នកដទៃ។
- ជៀសវាងឥរិយាបថដែលមានគ្រោះថ្នាក់ និងលើកទឹកចិត្តអ្នកដទៃទៀតដើម្បីជៀសវាងឥរិយាបថដែលមានគ្រោះថ្នាក់។

## ការចូលរួម

- មករៀនរៀងរាល់ថ្ងៃ (លុះត្រាតែត្រូវបានលើកលែងស្របច្បាប់)។
- មកដល់សាលា និងថ្នាក់រៀនទាន់ម៉ោង។
- ត្រៀមខ្លួនរៀនរាល់មេរៀនទាំងអស់។
- ចូលរួមយ៉ាងសកម្មក្នុងការរៀនសូត្រ។
- ប្រាថ្នា និងខិតខំសម្រេចឱ្យបាននូវស្តង់ដារខ្ពស់បំផុតនៃការរៀនសូត្រ។

នាយកសាលា និងបុគ្គលិកសាលា ដោយការប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយជំនាញវិជ្ជាជីវៈ មានសមត្ថភាពខ្ពស់បំផុតក្នុងរក្សាវិន័យ និងផ្តល់បរិយាកាសរៀនសូត្រដែលមានសុវត្ថិភាព ការគាំទ្រ និងការឆ្លើយតប។ ក្រសួងផ្តល់នូវក្របខ័ណ្ឌគោលនយោបាយ និងធនធាននានាដូចជាព្រឹត្តិបត្រអំពីបញ្ហាច្បាប់ ការទទួលបានការប្រឹក្សាពីអ្នកជំនាញ និងការរៀនជំនាញវិជ្ជាជីវៈដើម្បីណែនាំនាយកសាលា និងបុគ្គលិករបស់ខ្លួនក្នុងការអនុវត្តន៍ការវិនិច្ឆ័យប្រកបដោយជំនាញវិជ្ជាជីវៈ។ នៅក្នុងបរិបទនេះ រដ្ឋាភិបាលថ្នាក់រដ្ឋ NSW និង Department of Education នឹងគាំទ្រសិទ្ធិអំណាច និងការវិនិច្ឆ័យរបស់នាយកសាលា និងបុគ្គលិកសាលានៅតាមកម្រិតតំបន់។